

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា



## ដៃគូ

សាលារៀន និងសហគមន៍នឹងដើរតួយ៉ាងសំខាន់ក្នុងការអនុវត្តន៍គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជានេះដោយសារតែពួកគេជាអ្នកស្គាល់ច្បាស់នូវតម្រូវការ និងស្ថានភាពជាក់ស្តែងនៅក្នុងតំបន់របស់គម្រោង។ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ តាមរយៈអង្គការអប់រំពិភពលោក ដែលជាអង្គការដៃគូអនុវត្តនឹងធ្វើសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា ដែលជាដៃគូដ៏យូរអង្វែង និងអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) ដើម្បីផ្តល់នូវការគាំទ្រ ដែលសាលារៀន និងសហគមន៍ត្រូវការ ដើម្បីអនុវត្តគម្រោងប្រកបដោយប្រសិទ្ធិភាព។ អង្គការដៃគូក្នុងស្រុកដទៃទៀតក៏នឹងដើរតួដ៏សំខាន់ក្នុងការអនុវត្តន៍គម្រោងនេះផងដែរ។ ការងារជាច្រើននឹងត្រូវអនុវត្តតាមរយៈក្រុមការងារថ្នាក់ខេត្ត ដែលរួមមានតំណាងពីសហគមន៍ សាលាការិយាល័យអប់រំ យុវជន និង កីឡា ថ្នាក់ស្រុក និងថ្នាក់ខេត្តជាដៃគូ។ ក្រុមពិគ្រោះយោបល់ថ្នាក់ជាតិនឹងត្រូវរៀបចំដើម្បីធានាឱ្យមានការចូលរួមពីក្រសួងអប់រំ យុវជន និង កីឡា ថ្នាក់នាយកដ្ឋានពាក់ព័ន្ធលើការអនុវត្តន៍គម្រោងនេះ។ លើសពីនេះទៀតនោះ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ តាមរយៈអង្គការអប់រំពិភពលោកបានបង្កើតភាពជាដៃគូជាមួយអង្គការអន្តរជាតិពីរទៀត គឺអង្គការ អ៊ីខ្វល អាកសេស (Equal Access) និងវិទ្យាស្ថានស្រាវជ្រាវអាមេរិក (AIR) ហើយក៏មានអង្គការភាពជាដៃគូនៃអង្គការក្រៅរដ្ឋាភិបាល (NEP) សម្រាប់អនុវត្តកម្មវិធីពិសេស ដែលទាក់ទងទៅនឹងផ្នែកទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន។

## ទំនាក់ទំនងព័ត៌មាន

Kurt Bredenberg
World Education
Chief of Party
Email: kbredenberg@worlded.org.kh

Brian Levey
United States Agency for International Development (USAID)
Agreement Officer's Technical Representative (AOTR)
Email: blevey@usaid.gov

World Education Office: House # 20, Street 222, Phnom Penh, Cambodia
Tel: (855-23) 216 854 / Fax: 218 369 / E-mail: worldedcam@worlded.org.kh
Website: www.worlded.org

# សាវតារ

ថ្វីត្បិតតែប្រព័ន្ធអប់រំនៅកម្ពុជាមានការរីកចម្រើន និងសម្រេចបាននូវសមិទ្ធផលជាច្រើន តាមរយៈកំណែទម្រង់វិស័យអប់រំ និងកំណើនវិនិយោគរបស់រាជរដ្ឋាភិបាលលើវិស័យអប់រំតាំងពីឆ្នាំ ២០០១ មកក៏ដោយ ក៏ការប្រឈមដ៏គួរឱ្យកត់សម្គាល់មួយចំនួននៅតែមានទាក់ទងទៅនឹងភាពងាយស្រួលចូលសាលារៀន (អត្រាចូលរៀន) និងគុណភាពអប់រំ។ បញ្ហាទាំងនេះកើតឡើងជាពិសេសចំពោះកុមារដែលរស់នៅតំបន់ជនបទដាច់ស្រយាល និងកុមារដែលងាយរងគ្រោះ រួមមានកុមារក្រីក្រ កុមារជនជាតិភាគតិច និងកុមារី។ គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBECP) ដែលឧត្ថម្ភគាំទ្រដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) នឹងព្យាយាមដោះស្រាយបញ្ហាទាក់ទងនឹងអត្រាចូលរៀន និងគុណភាពអប់រំតាមរយៈយុទ្ធវិធីដោយផ្តោតទៅលើការអភិវឌ្ឍន៍កម្មវិធីគ្រប់វិស័យ ការអភិវឌ្ឍន៍ដែលដឹកនាំដោយអ្នកពាក់ព័ន្ធ ការកែលម្អការអប់រំ ដែលឆ្លើយតបទៅនឹងការរស់នៅក្នុងមូលដ្ឋាន និងការគ្រប់គ្រង។ គម្រោងនេះត្រូវបានរៀបចំឡើង ដោយផ្អែកតាមបទពិសោធន៍ល្អៗ ដែលទទួលបានពីគម្រោងគាំទ្រសេវាអប់រំសម្រាប់កុមារនៅតំបន់ដាច់ស្រយាល (ESCUP) និងគម្រោងសាលារៀនដើម្បីជីវិតរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ដែលអនុវត្តដោយអង្គការអប់រំពិភពលោកក្នុងរយៈពេលប្រាំឆ្នាំកន្លងមក ។



## សេចក្តីសង្ខេបរបស់គម្រោង



**គោលបំណង:** យុវវ័យមានការអប់រំកាន់តែប្រសើរ តាមរយៈការលើកកម្ពស់គុណភាពអប់រំ និងបង្កើនភាពងាយស្រួលចូលសាលារៀន ។

**រយៈពេល :** ប្រាំឆ្នាំ (ចាប់ពីខែតុលា ២០០៩ រហូតដល់ ខែកញ្ញា ២០១៤)
**ថវិកាសរុប :** ១០ លានដុល្លាសហរដ្ឋអាមេរិក
**គ្របដណ្តប់លើ :** ៣ខេត្ត គឺខេត្តកំពង់ចាម ក្រចេះ និងខេត្តសៀមរាប
**ក្រុមគោលដៅ :** សាលាបឋមសិក្សា ១៩៨ ដោយមានសិស្សានុសិស្ស ៦៥ ៧៣៦ នាក់ សាលាមធ្យមសិក្សា ១០៣ ដោយមានសិស្សានុសិស្ស ៥៥ ៤៨០ នាក់

**យុទ្ធវិធីសំខាន់ៗ :**
១ ការអភិវឌ្ឍន៍កម្មវិធីគ្រប់វិស័យ
២ យុទ្ធសាស្ត្របែងចែកលំដាប់ថ្នាក់ ផ្តោតសំខាន់ទៅលើអភិបាលកិច្ចល្អ (តាមសាលារៀន - អង្គការក្នុងស្រុកនានា)
៣ ការអភិវឌ្ឍន៍ដែលដឹកនាំដោយអ្នកពាក់ព័ន្ធ និងការផ្តល់សិទ្ធិអំណាចដល់មូលដ្ឋាន
៤ ទំនាក់ទំនងប្រតិបត្តិដោយស្របទៅតាមបរិបទមូលដ្ឋាន
៥ ភាពជាដៃគូជាមួយផ្នែកឯកជននានា
៦ ការស្វែងរកមតិគាំទ្រឱ្យបានទូលំទូលាយ និងមាននិរន្តរភាព

# ការរៀបចំគម្រោង

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាត្រូវបានរៀបចំឡើងក្នុងគោលបំណងធ្វើឱ្យយុវវ័យមានការអប់រំកាន់តែប្រសើរ លើកកម្ពស់គុណភាពអប់រំ និងសំដៅបង្កើនភាពងាយស្រួលចូលសាលារៀន។ សម្មតិកម្មនៃការអភិវឌ្ឍន៍ ដែលផ្តើមចេញពីយុទ្ធសាស្ត្របច្ចេកទេសរបស់គម្រោងក្នុងការបង្កើតភាពងាយស្រួលចូលសាលារៀន និងគុណភាពអប់រំ ទាមទារឱ្យគម្រោងធ្វើការឆ្លើយតបតាមរយៈអន្តរាគមន៍ជាច្រើនព្រមគ្នាទៅនឹងកត្តាតម្រូវការ និងកត្តាផ្គត់ផ្គង់ ទៅតាមវិធីមួយដែលជាការផ្ទេរអំណាចដល់អ្នកពាក់ព័ន្ធនៅមូលដ្ឋាន និងការកសាងនូវភាពជាម្ចាស់ទៅលើគម្រោង។ កត្តាទាំងនេះ ជាញឹកញាប់តែងតែផ្សារភ្ជាប់គ្នា ហើយប្រែប្រួលទៅតាមបរិបទមូលដ្ឋាន។ ដូចនេះ ការរៀបចំកម្មវិធីត្រូវប្រើយុទ្ធសាស្ត្រក្នុងការអនុវត្តន៍កម្មវិធីគ្រប់វិស័យមួយ ដែលមានភាពទន់ភ្លន់បត់បែនល្មម ក្នុងការឆ្លើយតបទៅនឹងតម្រូវការដែលកំណត់ដោយអ្នកពាក់ព័ន្ធនៅមូលដ្ឋាន ក៏ដូចជាការឆ្លើយតបទៅនឹងបរិបទគោលនយោបាយថ្នាក់ជាតិផងដែរ ។

ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ តាមរយៈអង្គការអប់រំពិភពលោក ព្រមទាំងដៃគូរួមការងារនឹងអនុវត្តគម្រោងដោយធ្វើយ៉ាងណាឱ្យកាន់តែប្រសើរ និងមានប្រសិទ្ធិភាពដែលស្របទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលនយោបាយសំខាន់ៗដែលទាក់ទងនឹងការងារទាំងនោះរួមមានគោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ជាតិ (២០០៣) គោលនយោបាយសាលាកុមារមេត្រី(២០០៨)និងគោលនយោបាយអប់រំបំណិនជីវិត (២០០៥)។ ការបង្កើនភាពងាយស្រួលចូលសាលារៀននឹងត្រូវបានឆ្លើយតបតាមរយៈអន្តរាគមន៍ជាច្រើនរួមគ្នា ពោលគឺកម្មវិធីអាហារូបករណ៍ ការសង់បង្គន់អនាម័យ ការផ្តល់ទឹកស្អាតនៅតាមសាលារៀន និងសកម្មភាពជំរុញការចុះឈ្មោះចូលរៀន ដោយប្រើកញ្ចប់ថវិកាសាលារៀន។ គោលបំណងក្នុងការលើកកម្ពស់គុណភាពអប់រំ នឹងត្រូវឆ្លើយតបតាមរយៈអន្តរាគមន៍ ដែលផ្តោតទៅលើកម្មវិធីសិក្សាបំណិនជីវិត កម្មវិធីបំប៉នគ្រូ និងការគ្រប់គ្រងសាលារៀន។

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជានឹងផ្តោតទៅលើសាលារៀននៅតំបន់ទីប្រជុំជន តំបន់ជនបទ និងតំបន់ដាច់ស្រយាល។ គម្រោងនេះក៏នឹងខិតខំផងដែរក្នុងការពង្រឹងសមត្ថភាពសង្គមស៊ីវិល មន្ត្រីថ្នាក់មូលដ្ឋាន និងអង្គការដៃគូ។ ដោយសារតែវាជាផ្នែកមួយនៃគម្រោងផងដែរនោះ ដៃគូការងារនៅតាមមូលដ្ឋាន នឹងទទួលបាននូវការកសាងសមត្ថភាព ដើម្បីសម្រេចបានដោយការទទួលស្គាល់ជាផ្លូវការ ដែលធ្វើឱ្យពួកគេអាចនឹងស្វែងរកថវិកាដោយផ្ទាល់ពីម្ចាស់ជំនួយ ទាំងពហុភាគី និងទ្វេភាគី ។

